**នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង**

**អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា**

ឯកសារបកប្រែ
TRANSLATION/TRADUCTION
ថ្ងៃ ខែ ឆ្នាំ (Date): 14-Oct-2014, 13:25
CMS/CFO: Sann Rada

**ព័ត៌មានពិស្តារអំពីការដាក់ឯកសារ**

សំណុំរឿងលេខ: ០០២/១៩-០៩-២០០៧-អ.វ.ត.ក/អ.ជ.ស.ដ

ភាគីដាក់ឯកសារ: សហមេធាវីរបស់លោក នួន ជា

ដាក់ជូន: សមាសភាពចៅក្រមពិសេសនៃអង្គជំនុំជម្រះសាលាដំបូង

ភាសាដើម: អង់គ្លេស

កាលបរិច្ឆេទឯកសារ: ថ្ងៃទី ១៤ ខែ តុលា ឆ្នាំ ២០១៤

**<u>ចំណាត់ថ្នាក់ឯកសារ</u>**

ចំណាត់ថ្នាក់ឯកសារ ស្នើឡើងដោយភាគីដាក់ឯកសារ: សាធារណៈ

ចំណាត់ថ្នាក់ឯកសារដោយអង្គជំនុំជម្រះសាលាដំបូង: **សាធារណៈ/Public**

ចំណាត់ថ្នាក់ប្រភេទឯកសារ:

ពិនិត្យឡើងវិញចំពោះឯកសារចំណាត់ថ្នាក់បណ្តោះអាសន្ន:

ឈ្មោះមន្ត្រីកត់ត្រា:

ហត្ថលេខា:

---

## សំណើរបស់ នួន ជា សុំឲ្យមានសាវនាការផ្ទាល់មាត់លើបណ្តឹងជំទាស់ចិត្តសុំដកចៅក្រម

---

**<u>ដាក់ដោយ:</u>**

**ក្រុមមេធាវីការពារក្តី នួន ជា**

សុន អរុណ
Victor KOPPE
ព្រុំ ផល្លា
សួន វិសាល
លីវ សុវណ្ណា
Doreen CHEN
Joshua ROSENSWEIG
Xiaoyang NIE
Sophie DAWSON

**<u>ចម្លងជូន:</u>**

**សហមេធាវី ខៀវ សំផន**

គង់ សំអុន
Arthur VERCKEN
Anta GUISSÉ

**សហព្រះរាជអាជ្ញា:**

ជា លាង
Nicholas KOUMJIAN

**<u>សហមេធាវី តំណាងដើមបណ្តឹងរដ្ឋប្បវេណី</u>**

ពេជ អង្គ
Marie GUIRAUD

## I. សេចក្តីផ្តើម

1. អនុលោមតាមមាត្រា ៨.៤ នៃ*សេចក្តីណែនាំអនុវត្តអំពីការដាក់ឯកសារនៅចំពោះមុខ អ.វ.ត.ក* (“សេចក្តីណែនាំអនុវត្ត”) សហមេធាវីការពារក្តីលោក នួន ជា (“មេធាវីការពារក្តី”) សូមដាក់សំណើសុំឱ្យមានសវនាការដេញដោលផ្ទាល់មាត់ទាក់ទងនឹងបណ្តឹងមិនទាន់សម្រេច ដែលបានស្នើសុំដកចៅក្រមជាក់លាក់ពីអង្គជំនុំជម្រះសាលាដំបូង។

## II. ប្រវត្តិនីតិវិធី

2. នៅថ្ងៃទី ១១ ខែ សីហា ឆ្នាំ ២០១៤ មេធាវីការពារក្តីបានជូនដំណឹងដល់អង្គជំនុំជម្រះថា ខ្លួននឹងដាក់បណ្តឹងជំទាស់ដើម្បីដកចៅក្រម និល ណុន ចៅក្រម យ៉ា សុខន ចៅក្រម Jean-Marc Lavergne និងចៅក្រម យូរ ឧត្តរា ចេញពីការជំនុំជម្រះសំណុំរឿង ០០២/០២ និងកិច្ចដំណើរការនីតិវិធីទាំងអស់ នៅក្នុងរឿងក្តី នួន ជា (“សេចក្តីជូនដំណឹងអំពីបណ្តឹងជំទាស់”)[1]។

3. នៅថ្ងៃទី ២៥ ខែ សីហា ឆ្នាំ ២០១៤ សហមេធាវីការពារក្តីរបស់លោក ខៀវ សំផន បានដាក់សំណើសុំផ្អាកដំណើរការនីតិវិធីក្នុងសំណុំរឿង ០០២/០២ រហូតដល់មានការសម្រេចចុងក្រោយលើសាលក្រមសំណុំរឿង ០០២/០១ ឬនិយាយម្យ៉ាងទៀតថា សុំដកចៅក្រមទាំងអស់ពីអង្គជំនុំជម្រះសាលាដំបូង (“សំណើលើកទីមួយរបស់ ខៀវ សំផន”)[2]។

4. នៅថ្ងៃទី ០៤ ខែ កញ្ញា ឆ្នាំ ២០១៤ គណៈកម្មាធិការរដ្ឋបាលតុលាការបានចាត់តាំងសមាសភាពចៅក្រមពិសេស (“សមាសភាពចៅក្រមពិសេស”) ដើម្បីសម្រេចលើបណ្តឹងជំទាស់ក្នុងពេលអនាគត និងសំណើលើកទីមួយរបស់ ខៀវ សំផន[3]។

---

[1] ឯកសារលេខ **E314.1** “សារអេឡិចត្រូនិចពី Doreen Chen ជូន Ken Roberts, ថ្ងៃទី១១ ខែ សីហា ឆ្នាំ ២០១៤។

[2] ឯកសារលេខ **E314/1** “សំណើរបស់លោក ខៀវ សំផន សុំឱ្យពិនិត្យឡើងវិញពីភាពចាំបាច់ក្នុងការរង់ចាំសាលក្រមក្នុងសំណុំរឿងចូលជាស្ថាពរ មុននឹងចាប់ផ្តើមការជំនុំជម្រះសំណុំរឿង ០០២/០២ និងសុំឱ្យពិនិត្យឡើងវិញពីការចាត់តាំងក្រុមជំនុំជម្រះថ្មីមួយ” ថ្ងៃទី២៥ ខែ សីហា ឆ្នាំ២០១៤។

[3] ឯកសារលេខ **E314/1** “សេចក្តីសម្រេចរបស់គណៈកម្មាធិការរដ្ឋបាលតុលាការទាក់ទងនឹងការចាត់តាំងសមាសភាពចៅក្រមដើម្បីពិនិត្យ និងវិនិច្ឆ័យលើបណ្តឹងជំទាស់ប្រឆាំងនឹងចៅក្រមអង្គជំនុំជម្រះសាលាដំបូង” ថ្ងៃទី០៤ ខែ កញ្ញា ឆ្នាំ២០១៤, ទំព័រ១។

5. នៅថ្ងៃទី ១៩ ខែ កញ្ញា ឆ្នាំ ២០១៤ អង្គជំនុំជម្រះសាលាដំបូងបានបដិសេធសំណើលើកទីមួយរបស់ ខៀវ សំផន សុំឲ្យផ្អាកដំណើការ និងទុកសំណើសុំដកចៅក្រមឲ្យសមាសភាពចៅក្រមពិសេសជាអ្នកសម្រេច[4]។

6. នៅថ្ងៃទី ២៩ ខែ កញ្ញា ឆ្នាំ ២០១៤ មេធាវីការពារក្តីបានដាក់បណ្តឹងជិតចិត្តដើម្បីដកចៅក្រម និល ណុន ចៅក្រម យ៉ា សុខន ចៅក្រម Jean-Marc Lavergne និងចៅក្រម យូ៉រ ឧត្តរា ចេញពីការជំនុំជម្រះសំណុំរឿង ០០២/០២ និងកិច្ចដំណើរការនីតិវិធីទាំងអស់ នៅក្នុងរឿងក្តី នួន ជា ("បណ្តឹងជិតចិត្ត")[5]។

7. នៅថ្ងៃទី ១០ ខែ តុលា ឆ្នាំ ២០១៤ សហមេធាវីការពារក្តីរបស់លោក ខៀវ សំផន បានដាក់សំណើជូនសមាសភាពចៅក្រមពិសេស ("សំណើសាជាថ្មី") ដោយបញ្ជាក់ជាថ្មីអំពីបណ្តឹងជិតចិត្តរបស់ខ្លួន និង បានស្នើសុំឲ្យមានសវនាការដេញដោលផ្ទាល់មាត់លើបញ្ហានេះ ដោយយោងទៅលើមូលដ្ឋាននៅកថាខណ្ឌ ១៣៖

> យោងទៅលើសារៈសំខាន់នៃបញ្ហាទាំងឡាយដែលត្រូវបានលើកឡើងដោយបណ្តឹងជិតចិត្ត ជាពិសេសតាមគោលការណ៍នៃការជំនុំជម្រះក្តីដោយយុត្តិធម៌ មេធាវីការពារក្តីស្នើសុំឲ្យក្រុមប្រឹក្សាជំនុំជម្រះពិសេសស្តាប់ទឡ្ហីករណ៍របស់ភាគីទាំងអស់ក្នុងអំឡុងពេលសវនាការសាធារណៈ។ សំណើនេះមានគោលបំណងឲ្យប្រជាជនខ្មែរបានយល់ និងបានតាមដានទស្សនាការពិភាក្សាដេញដោល[6]។

---

[4] ឯកសារលេខ **E314/1** "សេចក្តីសម្រេចលើសំណើរបស់ ខៀវ សំផន សុំពន្យារការចាប់ផ្តើមសំណុំរឿង ០០២/០២" ថ្ងៃទី ១៩ ខែ កញ្ញា ឆ្នាំ២០១៤ ។

[5] ឯកសារលេខ **E314/6** "បណ្តឹងជិតចិត្តរបស់ នួន ជា សុំដកចៅក្រម និល ណុន ចៅក្រម យ៉ា សុខន ចៅក្រម Jean-Marc Lavergne និងចៅក្រម យូ៉រ ឧត្តរា" ថ្ងៃទី ២៩ ខែ កញ្ញា ឆ្នាំ២០១៤។

[6] ឯកសារលេខ **E314/8** "បណ្តឹងជិតចិត្តសាជាថ្មី ប្រឆាំងនឹងសមាសភាពចៅក្រមបច្ចុប្បន្ននៃអង្គជំនុំជម្រះសាលាដំបូងដែលត្រូវសម្រេចលើសំណុំរឿង ០០២/០១" កថាខណ្ឌ១៣។ ដើម្បីជាការងាយស្រួលសម្រាប់សមាសភាពចៅក្រមពិសេស មេធាវីការពារក្តីបកប្រែក្រៅផ្លូវការពាក្យដែលដកស្រង់ដូចតទៅនេះ៖ "យោងទៅលើសារៈសំខាន់នៃបញ្ហាទាំងឡាយដែលត្រូវបានលើកឡើងដោយបណ្តឹងជិតចិត្ត ជាពិសេសតាមគោលការណ៍នៃការជំនុំជម្រះក្តីដោយយុត្តិធម៌ មេធាវីការពារក្តីស្នើសុំឲ្យក្រុមប្រឹក្សាជំនុំជម្រះពិសេសស្តាប់ទឡ្ហីករណ៍របស់ភាគីទាំងអស់ក្នុងអំឡុងពេលសវនាការសាធារណៈ។ សំណើនេះមានគោលបំណងឲ្យប្រជាជនខ្មែរបានយល់ និងបានតាមដានទស្សនាការពិភាក្សាដេញដោល"។

8. នៅថ្ងៃទី១០ ខែ តុលា ដូចគ្នា សហព្រះរាជអាជ្ញាបានដាក់ចម្លើយតបទៅនឹងបណ្តឹងជិតចិត្ត ("ចម្លើយតបរបស់សហព្រះរាជអាជ្ញា")[7]។

## III. ច្បាប់ជាធរមាន

9. ជាផ្នែកមួយនៃសិទ្ធិជាមូលដ្ឋានក្នុងការទទួលបានការជំនុំជម្រះក្តីដោយយុត្តិធម៌ ជនជាប់ចោទនៅចំពោះមុខ អវតក មានសិទ្ធិទទួលបាន "សវនាការដោយយុត្តិធម៌ និង *ជាសាធារណៈ*"[8]។ មាត្រា ៨.៤ នៃសេចក្តីណែនាំអនុវត្តបានអនុញ្ញាតឱ្យភាគីឆ្លើយតបទៅនឹងចម្លើយតប។ សេចក្តីណែនាំអនុវត្តក៏ពិចារណាផងដែរអំពីលទ្ធភាពឱ្យមានសវនាការជាសាធារណៈទាក់ទងទៅនឹងបណ្តឹងដែលបានដាក់ដោយភាគីថា "ការឆ្លើយតប[មួយ] ត្រូវបានអនុញ្ញាតតែក្នុងករណីដែលមិនមានការស្នើសុំឱ្យមានការដេញដោលដោយផ្ទាល់មាត់ប៉ុណ្ណោះ"។

## IV. ឧទ្ទិករណ៍

10. លោក នួន ជា មានសិទ្ធិស្នើសុំឱ្យមានសវនាការផ្ទាល់មាត់។ ដោយបានពិនិត្យចម្លើយតបរបស់សហព្រះរាជអាជ្ញា ក្រុមមេធាវីការពារយល់ឃើញថា ដើម្បីពិភាក្សាឱ្យបានត្រឹមត្រូវ និងគ្រប់ជ្រុងជ្រោយនូវការឆ្លើយតបរបស់ខ្លួនទៅនឹងចម្លើយតបរបស់សហព្រះរាជអាជ្ញា សវនាការផ្ទាល់មាត់គឺសំខាន់ ដោយផ្អែកលើមូលហេតុនានាដែលសហមេធាវីលោក ខៀវ សំផន បានលើកឡើងនៅក្នុងកថាខណ្ឌ១៣ នៃសំណើសាជាថ្មីរបស់ខ្លួន ដែលក្រុមមេធាវីការពារក្តីទទួលយក។

11. នៅក្នុងករណីដែលសមាសភាពចៅក្រមពិសេស មិនអនុញ្ញាតចំពោះសំណើនេះ ក្រុមមេធាវីការពារក្តីសូមជូនដំណឹងដល់សមាសភាពចៅក្រមពិសេសពីគោលបំណងរបស់ខ្លួន ក្នុងការដាក់ការឆ្លើយ

---

[7] ឯកសារលេខ **E314/9** "ចម្លើយតបរបស់សហព្រះរាជអាជ្ញាទៅនឹងបណ្តឹងជិតចិត្តរបស់ នួន ជា" ថ្ងៃទី ១០ ខែ តុលា ឆ្នាំ ២០១៤។

[8] កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ, មាត្រា ១៤(១)។ ច្បាប់បង្កើត អវតក មាត្រា ១០ថ្មី, ៣៣ថ្មី, ៣៥ថ្មី។ រដ្ឋធម្មនុញ្ញកម្ពុជា មាត្រាទី៣១។ ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា មាត្រា ៣១៦។

តបជាលាយលក្ខណ៍អក្សរទៅនឹងចម្លើយតបរបស់សហព្រះរាជអាជ្ញា។

## V. **សំណើសុំ**

12. យោងតាមហេតុផលដូចបានរៀបរាប់ខាងលើ មេធាវីការពារក្តីសូមស្នើឲ្យ **(i)** សមាសភាពចៅក្រមពិសេសទទួលយកសំណើសុំសវនាការផ្ទាល់មាត់ទាក់ទងនឹងបណ្តឹងជំទាស់ឥតចិត្តនេះ **(ii)** ដោយពិចារណាពីចរិតលក្ខណៈនៃបញ្ហានេះ សូមសមាសភាពចៅក្រមពិសេសជូនដំណឹងជាបន្ទាន់នូវសេចក្តីសម្រេចក្នុងទម្រង់ជាការឆ្លើយតបចំពោះសំណើនេះ។

សហមេធាវីការពារក្តីលោក នួន ជា

**សុន អរុណ** **Victor KOPPE**